# ធម្មតា II
# THOAMADA II

ថតដោយ វុធ លីណូ

Photographs by Vuth Lyno

# ធម្មតា II

# THOAMADA II


| | | | |
|---|---|---|---|
| ២ | អារម្ភកថា<br>លី ពិសី និង ស្រ៊ុន ស្រ៊ន | Preface<br>Ly Pisey and Srun Srorn | 3 |
| ៦ | *ធម្មតា II* ៖ ការសម្ដែងអំពីខ្លួនឯងដ៏ពិតប្រាកដ<br>អោក ព្រហ្មសុជន្ត | *Thoamada II*: Performing Our Realest Selves<br>Prumsodun Ok | 7 |
| ១០ | ក្ដីស្រឡាញ់នេះគឺធម្មតា<br>វៀត លេ | This Love is *Thoamada*<br>Việt Lê | 11 |
| ១៦ | រូបថត<br>វុធ លីណូ | Photographs<br>Vuth Lyno | 16 |

# អារម្ភកថា

## សាវតាប្រវត្តិសាស្ត្រ និងវប្បធម៌

ប្រទេសកម្ពុជា ជាប្រទេសមួយដែលស្ថិតក្នុងអាស៊ីអាគ្នេយ៍ និងត្រូវបានគេស្គាល់ច្រើនលើឆាកអន្តរជាតិដោយសារសង្គ្រាមស៊ីវិល ជាពិសេសរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ដែលបានសម្លាប់ជនស៊ីវិលស្លូតត្រង់ជាង ២ លាននាក់ ។ បន្ទាប់ពីរបបប្រល័យពូជសាសន៍នេះ កម្ពុជាបានកសាងរចនាសម្ព័ន្ធឡើងវិញពីបាតដៃទទេ ហើយប្រជាជនខ្មែរបាននិងកំពុងរស់នៅជាមួយភាពភ័យខ្លាច និងរបួសផ្លូវចិត្ត។ កម្ពុជា គឺជាប្រទេសមួយដែលមានអំណាចបិតាធិបតេយ្យខ្លាំង ហើយស្ត្រីនិងកុមារបន្តប្រឈមមុខនឹងអំពើហិង្សាក្នុងគ្រួសារ អំពើចាប់រំលោភ និងការចាប់រំលោភជាក្រុម។ ជំនឿបែបវប្បធម៌ នឹងបំរាមចាស់ៗនានា បន្តកំណត់បទដ្ឋានវប្បធម៌ជុំវិញយេនឌ័រ។ បទដ្ឋានទាំងនេះប៉ះពាល់យ៉ាងខ្លាំងដល់បែបបទនៃការគិត និងជំនឿរបស់ប្រជាជនខ្មែររហូតមកដល់សព្វថ្ងៃ។ ឧទាហរណ៍ ក្រុមភាគតូចដូចជាអ្នកស្រឡាញ់ភេទដូចគ្នា ត្រូវបានគេបោះត្រាថាជា «ខ្ទើយ» ហើយមកទល់សព្វថ្ងៃ ត្រូវបានគេមើលឃើញថាមានលក្ខណៈមិនធម្មជាតិ មិនប្រក្រតី និងជាមនុស្សដែលគ្មានអនាគតល្អប្រសើរនោះទេ។

## ទស្សនៈអវិជ្ជមានអំពីអ្នកស្រឡាញ់ភេទដូចគ្នា

ការរើសអើង និងការមើលងាយចំពោះអ្នកស្រឡាញ់ភេទដូចគ្នា (ស្រីស្រលាញ់ស្រី បុរសស្រលាញ់បុរស អ្នកស្រលាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ) នៅតែមានសភាពខ្លាំងក្លានៅក្នុងគ្រួសារ សហគមន៍ កន្លែងការងារ និងសង្គមទាំងមូល ដោយបដិសេធនិងបោះបង់ចោលអ្នកស្រឡាញ់ភេទដូចគ្នា។ អ្នកស្រឡាញ់ភេទដូចគ្នាភាគច្រើនជួបប្រទះនឹងការបំពានផ្លូវកាយនិងផ្លូវចិត្ត ប៉ុនប៉ងឬធ្វើអត្តឃាត ចូលរួមប្រើប្រាស់សារធាតុផ្សេងៗ ធ្វើចំណាកស្រុកនិងប្រឈមមុខនឹងហានិភ័យបន្ថែមទៀត ឬក៏ស្នាក់នៅក្នុងប្រទេសតែមានជម្រើសតិចតួចដើម្បីចិញ្ចឹមជីវិត។ បញ្ហានេះរុញច្រានពួកគេជាច្រើននាក់ឱ្យធ្លាក់ចូលក្នុងរបររកស៊ីផ្លូវភេទ។ ទាំងនេះគឺជាកត្តាជម្រុញដែលកើតចេញឡើងពីការមិនទទួលស្គាល់របស់គ្រួសារនិងសង្គម ហើយវាឆ្លុះបញ្ចាំងនូវភាពងាយរងគ្រោះកម្រិតខ្ពស់ ដែលអ្នកស្រឡាញ់ភេទដូចគ្នាត្រូវប្រឈមមុខ នៅក្នុងប្រទេសមួយដែលជីវិតប្រកបដោយភាពថ្លៃថ្នូរគឺជាបញ្ហាប្រឈមសម្រាប់មនុស្សភាគច្រើនបំផុត។

# Preface

**General historical and cultural background**

Cambodia, a country located in Southeast Asia, is mainly known globally because of the civil war, particularly the Khmer Rouge Regime (1975–1979), which killed more than two million innocent civilians. The country has reconstructed from zero after the genocide and Cambodian people have been living with much fear and trauma. Cambodia is a country of strong patriarchal dominance, where women and children continue to face domestic violence, rape and gang-rape. Traditional cultural beliefs and taboos continue to shape the cultural norms around gender. These norms strongly influence Cambodian peoples' ways of thinking and beliefs until today. For instance, marginalised groups like those who love the same sex are stamped as *ktoey*, and to this day are seen as unnatural and abnormal, and as people who will not have a good future.

**Negative views about LGBT**

Discrimination against and stigmatisation of those who love the same sex—lesbians, gays, bisexual and transgender (LGBT)—remains a strong force in families, communities, workplaces and society at large, denying and abandoning LGBT people. Many LGBT people experience physical and mental abuse, attempt or commit suicide, engage in substance abuse, migrate and face extra risks, or stay in Cambodia and have few options to carve out a livelihood. This pushes many into sex work. All of these are factors originated in family and societal rejection which highlight the greater levels of vulnerability faced by LGBT people, in a country where a life with dignity is a challenge for the vast majority of people.

**Why this book?**

Rainbow Community Kampuchea (RoCK) hopes to use this book as an educational tool to open up and correct the cultural taboos, wrong understandings and negative beliefs in Cambodian society, so that more people will see that people who love the same sex are *thoamada* (normal, usual). It is an instrument of communication, which explains to readers that once our society is inclusive, and LGBT people can be treated with dignity and equality—the same as straight people—then they will have opportunity to prove their talents, morality, skills and abilities for improved personal and family development, as well as helping to develop our society like everyone else. All kinds of human beings are the cells of the society, different in some ways but the same in other ways; every human being is a part of the whole. This is *thoamada* everywhere in the world.

## ហេតុអ្វីសៀវភៅនេះ ?

សហគមន៍ឥន្ទធនូកម្ពុជា (Rainbow Community Kampuchea - RoCK) សង្ឃឹមថាប្រើប្រាស់សៀវភៅនេះជាសម្ភារៈអប់រំមួយ ដើម្បីបើកចិត្ត និងកែតម្រូវបម្រាមវប្បធម៌ ការយល់ខុស និងជំនឿបែបអវិជ្ជមាននានាក្នុងសង្គមកម្ពុជា ដើម្បីឱ្យមនុស្សកាន់តែច្រើនមើលឃើញថា អ្នកស្រឡាញ់ភេទដូចគ្នាគឺ *ធម្មតា* ។ សៀវភៅនេះគឺជាឧបករណ៍មួយនៃការប្រាស្រ័យទាក់ទងរបស់យើងសម្រាប់ពន្យល់ដល់បណ្តាអ្នកអានថា កាលណាសង្គមរបស់យើងមានការបើកចំហ ហើយអ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានរាប់រកដោយសេចក្តីថ្លៃថ្នូរនិងសមភាព ពោលគឺដូចនឹងអ្នកស្រលាញ់ភេទផ្ទុយគ្នាដែរ នោះពួកគេនឹងមានឱកាសក្នុងការបញ្ចេញទេពកោសល្យ សីលធម៌ ជំនាញ និងសមត្ថភាពនានារបស់ពួកគេសម្រាប់ការអភិវឌ្ឍខ្លួនឯង និងគ្រួសារឱ្យកាន់តែប្រសើរ ក៏ដូចជាជួយអភិវឌ្ឍសង្គមរបស់យើងដូចអ្នកឯទៀតផងដែរ។ មនុស្សគ្រប់ប្រភេទ គឺជាកោសិការបស់សង្គម ខុសគ្នាក្នុងផ្លូវខ្លះប៉ុន្តែដូចគ្នាក្នុងផ្លូវច្រើន ដោយមនុស្សម្នាក់ៗគឺផ្នែកមួយនៃរូបភាពទាំងមូល។ នេះជារឿង *ធម្មតា* នៅគ្រប់ទីកន្លែងទាំងអស់លើពិភពលោក។

## ហេតុអ្វីបានជាយើងប្រើប្រាស់សិល្បៈ ?

តួនាទីរបស់សិល្បៈនៅក្នុងសង្គម គឺដើម្បីជួយសង្គមឱ្យលូតលាស់ និងស្វែងយល់ ដើម្បីមើលឃើញនូវរបស់ចាស់ៗតាមមធ្យោបាយថ្មីៗ ដោយបន្ថែមគុណតម្លៃពីជំនាន់មួយទៅជំនាន់មួយទៀត ។ សិល្បៈអាចបង្ហាញពីទស្សនៈវិស័យថ្មីនិងប្លែក តាមមធ្យោបាយប្រកបដោយសន្តិវិធី សុវត្ថិភាព និងគួរឱ្យចាប់អារម្មណ៍។ សិល្បៈ អាចពន្យល់រឿងរ៉ាវបានរាប់លានយ៉ាង!

## តើ RoCK ជានរណា? តើពួកយើងកំពុងធ្វើអ្វី ?

RoCK គឺជាសកម្មជនស្ម័គ្រចិត្តស្រឡាញ់ភេទដូចគ្នាមួយក្រុម ។ សហគមន៍នេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ 2009។ RoCK មានបំណងចង់ពង្រឹងតំណភ្ជាប់ និងការរួបរួមក្នុងចំណោមសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងសហគមន៍ធំជាងនេះ ដើម្បីនាំមកនូវការយល់ដឹង និងការចេញមុខកាន់តែច្រើនដល់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ទាំងនៅថ្នាក់តំបន់ និងថ្នាក់ជាតិ។ RoCK មានបំណងចង់កែប្រែការឈឺចាប់ និងភាពអាម៉ាស់នៃស្លាកស្នាមអវិជ្ជមាន និងការរើសអើងដែល អ្នកស្រឡាញ់ភេទដូចគ្នាជួបប្រទះ ឱ្យទៅជាមោទនភាព ទំនុកចិត្តលើខ្លួនឯង ភាពរីករាយ និងក្តីសង្ឃឹមសម្រាប់អនាគត របស់ពួកគេ និងអនាគតប្រទេសកម្ពុជាដែលកាន់តែមានក្តីស្រឡាញ់ និងបើកចំហ។


លី ពិសី និង ស្រ៊ុន ស្រ៊ន
សហគមន៍ឥន្ទធនូកម្ពុជា

**Why are we using the arts?**

The role of art in society is to help society to grow and learn, to see old things in new ways, adding value from one generation to another. Art can show new and different outlooks in peaceful, safe and interesting ways. The arts can explain a million things!

**Who is RoCK? What are we doing?**

RoCK is a voluntary group of LGBT activists. It was formed in 2009. RoCK aims to strengthen the connection and unity among the LGBT community and the wider community to bring more understanding and visibility of LGBT people into mainstream Cambodian society-locally and nationally. RoCK aims to transform the pain and shame of stigma and discrimination experienced by LGBT people into pride, self-confidence, joy and hope for their future and the future of a more loving and inclusive Cambodia.

Ly Pisey and Srun Srorn
Rainbow Community Kampuchea (RoCK)

# *ធម្មតា II*៖ ការសម្តែងអំពីខ្លួនឯងដ៏ពិតប្រាកដ

អោក ព្រហ្មសុជន្ត
សិល្បករ អ្នកនិពន្ធ គ្រូបង្រៀន

បន្ទាប់ពីសង្គ្រាមនិងការបំផ្លិចបំផ្លាញអស់រយៈពេលជាង ៣០ ឆ្នាំមក ប្រទេសកម្ពុជាបច្ចុប្បន្នគឺជាសង្គមមួយស្ថិតក្នុងការអភិវឌ្ឍដ៏ច្របូកច្របល់។ ក្នុងបរិយាកាសនៃការប្រែប្រួលមិនច្បាស់លាស់ និងយ៉ាងឆាប់រហ័សនេះ (មានដូចជាការបណ្តេញចេញទាំងបង្ខំ ការរំលោភបំពានសិទ្ធិប្រជាជន និងអសមធម៌ខ្លាំងក្លាជាដើម) សហគមន៍សិល្បៈដែលកំពុងរីកដុះដាល និងសហគមន៍ស្រីស្រឡាញ់ស្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ (អ្នកស្រលាញ់ភេទដូចគ្នា) ដែលទើបចងក្រងឡើងថ្មីៗនៅកម្ពុជា បានក្លាយទៅជាថ្នាលដ៏មានជីវជាតិបំផុតសម្រាប់ការផ្លាស់ប្តូរ និងការបង្កើតគំនិតថ្មីៗ។

នៅក្នុងស្នាដៃថ្មីចុងក្រោយរបស់សិល្បករ វ៉ុធ លីណូ ដែលមានចំណងជើងថា *ធម្មតា II* គាត់ប្រសព្វសហគមន៍ទាំងពីរនេះ ដោយការចងក្រងឯកសាររូបថតស្តីអំពីអ្នកស្រឡាញ់ភេទដូចគ្នា និងក្រុមគ្រួសាររបស់ពួកគេ។ គាត់ប្រើរូបថតពីរជាប់គ្នា ដែលក្រឡេកមើលដំបូងហាក់បីដូចជាបែបត្រង់ៗ សាមញ្ញ និងប្រើបែបថតផ្សេងគ្នាសម្រាប់រូបម្ខាងៗ។ ប៉ុន្តែពេលពិនិត្យមើលកាន់តែជិត គេនឹងឃើញថាការផ្គូរូបបែបសាមញ្ញនេះ បង្កើតជាសំណួរធំៗនិងលទ្ធភាពជាច្រើន សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាសម្រាប់ប្រទេសនេះផ្ទាល់ ក៏ដូចជាប្រទេសដទៃទៀតផងដែរ។

ពេលក្រឡេកមើលរូបភាពនៅផ្នែកខាងឆ្វេងនៃរូបថតជាគូទាំងនេះ គេនឹងឃើញមានតួអង្គនៅតែឯងឬជាមួយដៃគូ។ វាគឺជាផ្ទាំងរូបមួយ និងជាលំហរូបមួយ ដែលមានលក្ខណៈផ្ទាល់ខ្លួន និងស្និទ្ធស្នាល។ ឧទាហរណ៍ បុរសស្រឡាញ់បុរសវ័យក្មេងម្នាក់កំពុងសំកាំងខ្លួននៅកណ្តាលអាកាស និងនៅក្នុងការស្រមើស្រមៃរបស់គាត់ ហាក់ដូចជាមេអំបៅ។ ស្ត្រីស្រឡាញ់ស្ត្រីពីរនាក់ បង្ហាញក្នុងរូបភាពដូចជាផ្ទាំងគំនូរ កំពុងចែករំលែកអាហារដ៏តិចតួច។ បុរសម្នាក់បង្ហាញអំពីយុវវ័យមិនងាករេរបស់ខ្លួនតាមរយៈការច្រៀង។ រូបភាពទាំងនេះបង្ហាញពីរសនៃការសម្តែង ដែលពេលខ្លះមានលក្ខណៈជាអក្សរសិល្ប៍ ជាភាពយន្ត និងជានិមិត្តរូប ដូចជាពេលដែលគូស្នេហ៍វ័យកណ្តាលពីរនាក់កំពុងចែចង់គ្នាតាមបង្អួចខ្ទមជរាមួយជាដើម។

ក្នុងរូបថតមួយចំនួន តួអង្គក៏ហាក់ដូចជាសម្តែងតាមតួនាទីយេនឌ័រដែលកំនត់ដោយសង្គមផងដែរ។ *ស្រីចរិកប្រុស* និង*ស្រីចរិកស្រី* *បុរស* និង*ស្ត្រី* *ប្តី* និង*ប្រពន្ធ* អត្តសញ្ញាណទាំងនេះអាចមើលឃើញបានតាមរយៈម៉ូតសក់ សំលៀកបំពាក់ ឥរិយាបថ និងកត្តាផ្សេងទៀត។ សូម្បីតែបុរសកំពុងច្រៀង មានស្លៀកសារ៉ុងដែលជារឿងធម្មតាសម្រាប់បុរសខ្មែរក៏ហាក់ដូចជាបង្ហាញនូវតួអង្គតារាចម្រៀងសម្លេងមាសអស្ចារ្យជាងជីវិតពិតកំពុងស្ថិតនៅកណ្តាលចំណាប់អារម្មណ៍។ ចំណុចទាំងនេះចោទជាសំណួរថា៖ តើយើងពិតជាខ្លួនយើងមែនឬអត់ ក្នុងការបំពេញតួនាទីតាមបេត់របស់

# *Thoamada II*: Performing Our Realest Selves

Prumsodun Ok
Interdisciplinary Artist, Writer, Teacher

Today, after over thirty years of war and devastation, Cambodia is a society in tumultuous development. In this environment of rapid, uncertain change—one of forced evictions, civil rights abuses, and extreme inequality—the country's burgeoning art and newly forming lesbian, gay, bisexual, and transgender (LGBT) communities have become a most fertile hotbed for the exchange and development of new ideas.

In *Thoamada II*, Vuth Lyno's latest project, the artist intersects these two communities by documenting self-identifying LGBT persons and their families. He does so in a series of diptych portraits that at first glance seem candid, simple, and dualistic in approach. With closer study though, one will find that these minimal pairings yield large questions and possibilities for LGBT peoples in Cambodia, for the country itself, and beyond.

When looking at the images on the left-hand side of these diptychs, one will find the subjects alone or with a partner. It is a photographic plane, an image space that is personal and intimate: a young gay man hovers mid-air, and in his imagination, like a butterfly; two lesbian women, portrayed in a most painterly quality, share a meager meal; a man reveals his unwavering youth in the act of song. These images demonstrate a strong sense of performance, one that is at times literary, cinematic, and iconic, like when two middle-aged lovers court each other through the window of a rusted shack.

In several photographs, the subjects also appear to perform prescribed roles of gender. *Butch* and *femme*, *man* and *woman*, *husband* and *wife*—these identities become visible in hairstyle, in clothing, in posture, and more. Even the man singing, donning a sarong that is common for Khmer men, seems to hint at a larger than life diva in the limelight. This begs the question: are we our realest selves in the performance of social and gender cues? Are we our truest selves when performing our internal universe, our secret desires, our identities that seemingly defy the bodies and environments we were born into?

In the right-hand images of these diptychs, these subject-performers are featured among their families. They take on new roles, of a son to his loving mother, of daughters, of mothers and grandmothers, and more. To this exception is the singing gay man who now appears alone, but even he, smiling with a gentle contentment, has a family as teachers are often respected as guiding fathers and mothers in Khmer culture.

សង្គមនិងយេនឌ័រ? តើយើងពិតជាខ្លួនយើងដោយស្មោះត្រង់មែនឬអត់ នៅពេលអនុវត្តតាមពិភពខាងក្នុងរបស់យើង តាមសេចក្តីប្រាថ្នាលាក់កំបាំងរបស់យើង តាមអត្តសញ្ញាណរបស់យើងដែលហាក់ដូចជាជំនះលើរូបកាយ និងបរិស្ថាននានាដែលយើងកើតនៅក្នុង?

ក្នុងរូបភាពខាងស្តាំនៃរូបថតជាគូទាំងនេះ អ្នកសម្តែងតួអង្គទាំងនេះត្រូវបានបង្ហាញជាមួយគ្រួសាររបស់គាត់។ ពួកគេចាប់យកតួនាទីថ្មីដូចជា ជាកូនប្រុសនៃម្តាយជាទីស្រឡាញ់របស់គេ ជាកូនស្រី ជាម្តាយ និងជាជីដូនជាដើម។ ចំពោះចំណុចនេះ ករណីលើកលែងគឺមានតែបុរសស្រឡាញ់បុរសដែលច្រៀងប៉ុណ្ណោះ ដែលឥឡូវនេះលេចមុខតែម្នាក់ឯង។ ប៉ុន្តែជាមួយនឹងស្នាមញញឹមដែលពោរពេញទៅភាពសប្បាយចិត្តដ៏ទន់ភ្លន់ សូម្បីតែគាត់ក៏មានគ្រួសារមួយដែរក្នុងនាមជាគ្រូបង្រៀន ពីព្រោះនៅក្នុងវប្បធម៌ខ្មែរ គេច្រើនតែគោរពគ្រូដូចជាឳពុកម្តាយដឹកនាំផ្លូវផងដែរ។

អ្វីដែលជាលទ្ធផលនោះ គឺជារូបភាពនៃសមាហរណកម្មសង្គមដោយសុខដុម ដែលបង្ហាញឱ្យឃើញអំពីសហគមន៍មួយដែលវេញត្របាញ់នៅក្នុងស្រទាប់ខ្សែជីវិតខ្មែរបច្ចុប្បន្ន។ មានតួអង្គជាអ្នកត្បាញផាមួង ដែលជាក្រំណាត់និមិត្តរូបនៃប្រពៃណីនិងអត្តសញ្ញាណ ក៏ដូចជាតួអង្គយុវជនទីក្រុង និងតួអង្គផ្សេងៗទៀត។ ជាមួយនឹងក្រុមគ្រួសាររបស់ខ្លួន ពួកគេឆ្លុះបញ្ចាំងពីវិសាលគមនៃលក្ខខណ្ឌសេដ្ឋកិច្ច រួមទាំងអ្នកនៅជនបទ និងអ្នកនៅទីក្រុង ហើយលាតត្រដាងពីពិភពមួយដែលរួមគ្នាចងភ្ជាប់រង្វង់នៃអាយុ ពូជសាសន៍ ឋានៈ និងសញ្ជាតិ។

វាងាយស្រួលទេដែលមានមនុស្សជាច្រើននឹងមើលទៅស្នាដៃ *ធម្មតា II* ថាជាការប្រៀបធៀបសាមញ្ញមួយនៃមជ្ឈដ្ឋានផ្ទាល់ខ្លួន និងមជ្ឈដ្ឋានសាធារណៈ ក្នុងនាមជាការប្រឆាំងរវាងបំណងប្រាថ្នារបស់យើងជាមួយនឹងកាតព្វកិច្ចសង្គម និងរវាងបុគ្គលជាមួយនឹងសង្គម។ តែទោះជាយ៉ាងណា ដោយថតផ្តិតយកនូវរូបភាពបែបសម្តែងក្នុងចំណោមតួអង្គរបស់គាត់ និងរូបភាពស្ថានការដ៏ចំឡែករវាងការពិតនិងសិប្បនិម្មិតដែលតួអង្គនីមួយៗសម្តែងចេញ លីណូ ធ្វើឱ្យវត្តមានរបស់គាត់លេចចេញនៅក្នុងរូបភាពនីមួយៗ។ គឺរូបគាត់ ក្នុងនាមជាសិល្បករ ដែលបានស្នើឱ្យបុរសវ័យក្មេងលោតឡើងដូចជាមេអំបៅឱ្យគាត់ និងម៉ាស៊ីនថតរបស់គាត់។ គឺលីណូក្នុងនាមជាបុរសខ្មែរ ដែលបានស្នើឱ្យបុរសម្នាក់ទៀតច្រៀង។ គឺលីណូពេលខ្លះក្នុងនាមជាមិត្តភក្តិ និងពេលខ្លះទៀតជាមនុស្សដទៃ ដែលសុំចូលទៅក្នុងផ្ទះរបស់អ្នកទាំងអស់នេះ។

ដូច្នេះ *ធម្មតា II* គឺជារឿងរ៉ាវរបស់សិល្បករមួយរូប ដែលមានម៉ាស៊ីនថតនៅក្នុងដៃ ថតដងស្រង់ឯកសារ និងអបអរសង្គមមួយដែលកំពុងផ្លាស់ប្តូរយ៉ាងខ្លាំងក្លា។ ខណៈពេលពេលអ្នកស្រឡាញ់ភេទដូចគ្នានៅជុំវិញពិភពលោក កំពុងតស៊ូប្រឆាំងនឹងច្បាប់ដែលរើសអើងប្រឆាំងអ្នកស្រឡាញ់ភេទដូចគ្នា និងតស៊ូឱ្យមានសមភាពអាពាហ៍ពិពាហ៍ លីណូ ផ្តល់ឱ្យយើងនូវរូបភាពបែបស្រាលក្នុងស្មារតី តាមរយៈការបង្ហាញសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ ហើយដោយការធ្វើដូច្នេះ សិល្បកររូបនេះផ្តល់នូវអំណាចដល់សហគមន៍របស់គាត់ តាមរយៈរូបភាពបែបមនុស្សជាតិដែលមានគូស្នេហ៍រីករាយនិងមិនប្រេះឆា គ្រួសារមានសុភមង្គល និងអញ្ជើញមនុស្សនៅទូទាំងពិភពលោក ឱ្យមកនឹកគិតដល់អនាគតយុត្តិធម៌ សម្រាប់រាល់សមាជិកទាំងអស់នៃសង្គមរបស់ពួកគេ។

What results are images of harmonious social integration, illustrating a community interwoven into the fabric of contemporary Khmer life. The subjects are weavers of *pamuong*—textiles symbolic of tradition and identity—as well as urban youth and more. Along with their families, they inhabit a spectrum of economic positions, both rural and urban, and reveal a world that ties together spheres of age, race, class, and nationality.

It is easy to see how many will view *Thoamada II* as a simple contrasting of personal and public space, as an opposition of our desires against social obligation and the individual against society. However, by capturing a heightened sense of performance amongst his subjects and, in doing so, the ironic state of truth and artificiality that each subject embodies, Vuth makes his presence known within each image. It is he, the artist, who has asked the young man to jump up like a butterfly for him and his camera. It is Vuth, a Khmer man, who has asked another to sing. It is Vuth, at times as a friend and at others as a stranger, who has asked to come into these people's homes.

*Thoamada II* then, is the story of an artist who, camera in hand, documents and celebrates a society in great transition. As LGBT peoples across the globe struggle against anti-homosexuality laws and fight for marriage equality, Vuth offers us images that are light in spirit as he portrays the LGBT community of Cambodia. And, by doing so, the artist empowers his community with humanizing images of happy lovers and intact, healthy families, inviting people the world over to imagine just futures for all members of their society.

# ក្តីស្រឡាញ់នេះគឺធម្មតា


## វៀត លេ

សិល្បករ អ្នករៀបចំពិព័រណ៍សិល្បៈឯករាជ្យ ជំនួយការសាស្ត្រាចារ្យនៃមហាវិទ្យាល័យសិល្បៈកាលីហ្វ័រញ៉ា


នៅក្នុងស្នាដៃរូបថតជាគូរៗទំហំធំ ដែលមានចំណងជើងថា *ធម្មតា II* (២០១៣) វុធ លីណូ បង្ហាញតួអង្គក្នុងតវិយាបថធ្វើអោយយើងគិតពិចារណា និងពង្រីកការយល់ដឹងរបស់យើងអំពីបញ្ហាផ្លូវភេទ គ្រួសារ និងការចងចាំ។

ស្នាដៃនេះ គឺជាលទ្ធផលបន្តពីស្នាដៃមុននៃរូបថតនិងសំលេងអំពីបុគ្គលបុរសស្រឡាញ់បុរសមួយចំនួន ដែលមានចំណងជើងថា *ធម្មតា* (២០១១)។ *ធម្មតា* រួមមានរូបថតពណ៌ទំហំធំ និងឯកសារសម្លេងដែលព្យួរជារង្វង់។ ស្នាដៃនេះចោទសួរពីព្រំដែនរវាងភាពជាឯកជននិងសាធារណៈ ភាពខាងក្នុងនិងខាងក្រៅ។ រូបថតនៃមុខរបស់បុគ្គលទាំងនេះ មានបង្ហាញនៅខាងក្នុងរង្វង់ផង និងខាងក្រៅរង្វង់ផង ប៉ុន្តែសម្ព័ន្ធភាពរបស់អ្នកទស្សនាជាមួយរូបថតទាំងនោះមានភាពខុសគ្នា រវាងពីខាងក្នុងនិងខាងក្រៅ។ រូបថត និងរឿងរ៉ាវផ្ទាល់ខ្លួនរបស់បុគ្គលទាំងនោះ កើតចេញពីសិក្ខាសាលាខ្លីមួយ ដែលត្រូវបានរៀបចំជាមួយអ្នកសម្របសម្រួលអាជីពម្នាក់ និងបុរសស្រឡាញ់បុរសចំនួន ៩ នាក់ ដែលបានផ្លាស់ប្តូររឿងរ៉ាវជីវិតផ្ទាល់ខ្លួននានាក្នុងរយៈពេលពីរថ្ងៃ ក្នុងគោលបំណងបង្កើតនូវការសន្ទនាសាធារណៈដ៏ស្និទ្ធស្នាលមួយ អំពីនិងនៅក្នុងចំណោមសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (ស្រីស្រឡាញ់ស្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ)។

នៅក្នុងស្នាដៃបែបសហការទាំងពីរនេះ តួអង្គនៅក្នុងរូបថតបង្ហាញពីជីវិតរបស់ពួកគេបែបជា*ធម្មតា* គឺសាមញ្ញ ទូទៅ រៀងរាល់ថ្ងៃ។ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាខ្មែរទាំងនេះ មានសំលេងផ្សេងៗគ្នា។ លីណូ ស្នើឱ្យយើងក្នុងនាមជាបុគ្គលនិងជាក្រុម ពិចារណាឡើងវិញអំពីព្រំដែននៃក្តីស្រឡាញ់។ លីណូ ចែករំលែកអំពីរបៀបធ្វើការងាររបស់គាត់នៅក្នុងសម្រង់បទសម្ភាសន៍ខាងក្រោម៖

**តើដំណើរការរបស់លោកក្នុងការធ្វើការជាមួយបុគ្គលនៅក្នុងរូបថត ប្រព្រឹត្តទៅយ៉ាងដូចម្តេច?**

*ខ្ញុំបានសម្ភាសជាមួយគាត់នឹងក្រុមគ្រួសាររបស់គាត់ ដោយស្នើអោយគាត់រៀបរាប់ពីដំណើរជីវិត និងរឿងរ៉ាវរបស់គាត់។ បន្ទាប់ពីសន្ទនារួច ខ្ញុំបានអញ្ជើញគាត់ដើម្បីថតរូប ២ សន្លឹកផ្សេងគ្នា។ រូបទី១ គឺជារូបលក្ខណៈគ្រួសារសាមញ្ញនៅក្នុងផ្ទះរបស់គាត់។ ពួកគាត់បានសម្រេចចិត្តក្នុងការស្លៀកពាក់ និងអង្គុយដោយខ្លួនគាត់។*

*សម្រាប់រូបថតទី ២ ខ្ញុំបានស្នើឱ្យគាត់ជ្រើសរើសរួមគ្នានូវការចងចាំមួយ ហើយសម្តែងជាឈុតឆាកឡើងវិញ ដោយប្រើប្រាស់សម្ភារៈនិងទីតាំងនៅជុំវិញផ្ទះ។ ខ្ញុំបានស្នើឱ្យពួកគាត់ ជ្រើសរើសខណៈពេលគួរឱ្យចងចាំបំផុតមួយក្នុងជីវិតជាបុគ្គលឬជាគ្រួសារ។ យើងបានបង្កើតឈុតឆាក*

# This Love is *Thoamada*

Việt Lê
Artist, Independent Curator, Assistant Professor at California College of the Arts

In a series of evocatively posed, large photographic diptychs entitled *Thoamada II* (2013), Vuth Lyno expands common frameworks of sexuality, family, and memory.

This work is an outgrowth of an earlier series of photographic and audio portraits of individual MSM (men who have sex with men) entitled *Thoamada* (2011). *Thoamada* comprises a suspended circle of nine large-scale color photographic portraits and audio material. This work questions the line between private and public, inner and outer—the same faces appear inside and outside the circle, but your relationship to them differs. The portraits and stories derive from an intensive workshop with a professional facilitator and nine men who have sex with men (MSM) who exchanged personal stories over two days with the aim to build intimate public dialogue about, and among, LGBT (lesbian, gay, bisexual and transgender) communities.

In both collaborative series, subjects represent their lives as *thoamada*—normal, everyday, commonplace. These Khmer LGBT communities have diverse voices. Vuth asks us—individually and collectively— to reconsider the bounds of love. In an interview excerpt, Vuth shares his approach.

**What was your process working with your subjects?**

*I interviewed people together with their families, inviting them to share their stories and journey. After the conversation, I asked them to pose for two different photographs. One was a simple family portrait inside their house. They decided on their dress and pose.*

*For the second photograph, I asked them to collectively choose a memory to re-enact, improvised with their belongings and surroundings. I proposed that they select one of their most memorable moments in life as an individual or as a family. We re-created that scene together. Some chose a story they shared in the earlier interview, some chose another memory. Together we worked out clothing, and prepared a backdrop around the house to match with scene they remembered. Then they performed that moment and I took the photo.*

**How did you find your subjects?**

*Some of the participants I met before during Cambodia Pride over the last few years. Some were introduced to me through Cambodian LGBT networks. A few are my friends or were introduced to me through friends.*

*នោះឡើងវិញជាមួយគ្នា។ អ្នកខ្លះ បានជ្រើសរើសរឿងរ៉ាវមួយដែលពួកគេបានចែករំលែកនៅក្នុងបទសម្ភាសន៍ ឯអ្នកខ្លះទៀតបានជ្រើសរើសការចងចាំថ្មីផ្សេងទៀត។ យើងបានរួមគ្នាជ្រើសរើសសំលៀកបំពាក់ និងរៀបចំទីតាំងថតនៅជុំវិញផ្ទះ ដើម្បីឱ្យត្រូវជាមួយនឹងឆាកដែលពួកគេបានចងចាំ។ រួចមកពួកគេបានសម្តែងនូវឈុតឆាកមួយនោះ ហើយខ្ញុំក៏ថតរូប។*

### តើលោករកបានអ្នកចូលរួមថតរូបដោយរបៀបណា ?

*ខ្ញុំបានជួបអ្នកចូលរួមមួយចំនួនក្នុងអំឡុងពេលកម្មវិធីសប្តាហ៍មោទនភាពកម្ពុជា កាលពីពីរបីឆ្នាំមុន។ អ្នកមួយចំនួនទៀត មានគេណែនាំមកខ្ញុំតាមរយៈបណ្តាញអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ អ្នកខ្លះជាមិត្តភក្តិរបស់ខ្ញុំ ឬខ្ញុំស្គាល់តាមរយៈមិត្តភក្តិរបស់ខ្ញុំ។*

### តើនរណាជាទស្សនិកជនគោលដៅសម្រាប់រូបថតទាំងនេះ ?

*ខ្ញុំចង់បង្ហាញដល់ប្រជាជនខ្មែរជាចំបង។ ខ្ញុំចង់ឱ្យពួកគេឃើញរូបថតគ្រួសារទាំងនេះ ថាជាគ្រួសារបែបសាមញ្ញដូចគេទូទៅដែរ ថាពួកគាត់ទាំងអស់គ្នាគឺ «ធម្មតា» ។*

*រូបថតនៅខាងឆ្វេងគឺជាការរំលឹកឡើងវិញបែបអត្ថាធិប្បាយជាអ្វីម្យ៉ាងដែលទាក់ទង ឬមិនទាក់ទងនឹងបញ្ហាផ្លូវភេទរបស់គាត់ ប៉ុន្តែខ្ញុំយល់ថាវាសំខាន់ខ្លាំងណាស់ ព្រោះវាឆ្លុះបញ្ចាំងមួយផ្នែកឱ្យដឹងថាតើពួកគេកំណត់ខ្លួនឯងយ៉ាងដូចម្តេច និងជាផ្នែកមួយនៃដំណើរជីវិតក្នុងការកសាងក្រុមគ្រួសាររបស់ពួកគេ។*

### តើស្នាដៃ ធម្មតា II ផ្លាស់ប្តូរទស្សនៈ «បុរាណ» អំពីការកសាងក្រុមគ្រួសារដោយរបៀបណា ?

*បទពិសោធន៍របស់ខ្ញុំជាមួយអ្នកចូលរួមក្នុងគម្រោងរូបថតនេះមានសារៈប្រយោជន៍យ៉ាងខ្លាំង ហើយខ្ញុំបានរៀនយ៉ាងច្រើន។ គ្រួសារនីមួយៗកំនត់នូវអត្ថន័យនៃគ្រួសារ ការយល់ឃើញអំពីតួនាទីយេនឌ័រនិងរចនាសម្ព័ន្ធគ្រួសារ និងគំនិតនានាស្តីពីកត្តាដែលនាំអោយមានក្រុមគ្រួសារល្អ។ មានគ្រួសារដែលមានម្តាយពីរនាក់ មានគ្រួសារស្រីស្រឡាញ់ស្រីដែលម្នាក់ជាឪពុកនិងម្នាក់ទៀតជាម្តាយ  មានគ្រួសារដែលមានកូនប្រុសជាអ្នកស្រឡាញ់ភេទដូចគ្នាម្នាក់ និងកូនម្នាក់ទៀតជាអ្នកប្តូរភេទ  មានគ្រួសារដែលមានម្តាយជាអតីតទាហាន និងកូនស្រីជាអ្នកស្រឡាញ់ស្រីដូចគ្នា។ ចំណុចទាំងអស់នេះ ពិតជាតវ៉ាយ៉ាងខ្លាំងក្លាទៅនឹងការរំពឹងទុករបស់សង្គមចំពោះបែបផែននៃបុរសនិងស្ត្រី។*

### តើមានការឆ្លើយឆ្លង រឿងរ៉ាវ ឬក៏ការចងចាំសំខាន់ៗដែលលោកចង់ចែករំលែកដែរឬទេ ?

*គ្រួសារនីមួយៗបានចែករំលែករឿងរ៉ាវគួរឱ្យចាប់អារម្មណ៍។ ពេលខ្លះ គាត់មួយចំនួនមានការរំជួលចិត្តខ្លាំង ហើយខ្ញុំក៏ដូចគ្នាដែរ។ ឧទាហរណ៍ក្នុងគ្រួសារមួយ ពិសីបានចងចាំថា ពេលនាងនៅតូច នាងតែងតែរង់ចាំម្តាយទាហានរបស់នាងត្រឡប់មកផ្ទះវិញ ខណៈពេលដែលម្តាយកំពុងនៅសមរភូមិ។ ថ្ងៃនេះ នាងប្រាប់ម្តាយរបស់នាងថា ឥឡូវនេះវាគឺជាវេនរបស់នាងម្តងដើម្បីតស៊ូ តែមិនមែននៅលើសមរភូមិជាមួយសត្រូវនោះទេ គឺតស៊ូមតិដើម្បីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។*

**Who are the intended audiences for these images?**

*I wish to connect mainly to Cambodians. I want them to see these family portraits as common, like any other: they are all 'thoamada.'*

*The image on the left is a narrative recollection, something that may or may not related to the subject's sexuality, but I find it very significant—it reflects a part of how they define themselves and a part of the journey in shaping their family.*

**How does Thoamada II shift "traditional" ideas of what makes a family?**

*My experiences with all the participants were extremely rewarding and I have learned so much. Each family determines their own definition of family, notions of gender roles and family structure, and ideas of what leads to a good family. There were families with two mothers, there were lesbian families with one as a father and another as a mother, there was a family with a gay son who also had a transgender sibling, there was a family with an ex-soldier mother and a lesbian daughter. All these challenge stereotypes a great deal.*

**Are there any significant interactions, stories, or memories you'd like to share?**

*Each family shared a fascinating story. At times, some participants got very emotional, and me too. For example, in one family, Pisey remembered that when she was little she was always waiting for her soldier mother to come home, while the mother was in the battlefield. Today, she tells her mother that it's now her turn to conquer—not on a battlefield with the enemy—but in advocating for rights for Cambodian LGBT people.*

*[In another family], a lesbian couple remembered how one woman came asking for salt from the other at a meager meal during the Khmer Rouge regime. As resources were scarce, the woman refused, which made the other like her more, and they married soon after the Khmer Rouge lost power. Now they have adopted two daughters and one son with several grandchildren.*

**How has Khmer LGBT visibility and acceptance changed? What are current obstacles?**

*I noticed that Khmer LGBT visibility has increased dramatically over the past five years. The work by volunteer-based groups such as the Rainbow Community Kampuchea (RoCK), which organizes Cambodia's annual Pride, has been playing a critical role. Many Khmer lesbians, transgenders and gays throughout the country now have opportunities to meet, build networks, organize and voice their concerns in public forums.*

*Nevertheless, there are many different levels of obstacles ranging from family rejection, community discrimination to social neglect. Other roadblocks include negative attitudes towards LGBT and poor legal protection. Despite the generally tolerant culture, and that young people tend to be more open and accepting than older people, Cambodia is still a conservative society. People seek acceptance and fear society's rejection. But society starts with families. Change must start from acceptance at the family level.*

*ក្នុងគ្រួសារមួយទៀតដែលជាស្រីស្រឡាញ់ស្រី បានចាំថាម្នាក់បានទៅសុំអំបិលពីម្នាក់ទៀត ពេលកំពុងហូបអាហារដ៏ខ្សត់ខ្សោយក្នុងរបបខ្មែរក្រហម។ ដោយសារធនធានមានភាពខ្វះខាត គាត់បានបដិសេធមិនអោយ ដែលធ្វើឱ្យម្នាក់ទៀតចូលចិត្តគាត់កាន់តែខ្លាំងឡើង ហើយពួកគេបានរៀបអាពាហ៍ពិពាហ៍ មិនយូរប៉ុន្មានបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ។ បច្ចុប្បន្ន ពួកគាត់មានកូនចិញ្ចឹមស្រី ២ នាក់ និងប្រុសម្នាក់ ហើយមានចៅប្អូនប្រាំនាក់ទៀត។*

**តើការចេញមុខ និងការទទួលស្គាល់នៃអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាបានផ្លាស់ប្តូរយ៉ាងណាខ្លះ? តើបច្ចុប្បន្ននៅមានឧបសគ្គអ្វីខ្លះ?**

*ខ្ញុំបានកត់សម្គាល់ឃើញថា ការចេញមុខរបស់អ្នកស្រឡាញ់ភេទដូចគ្នាខ្មែរ បានកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ។ ការងាររបស់បណ្តាញក្រុមអ្នកស្ម័គ្រចិត្តដូចជា សហគមន៍ឥន្ទធនូកម្ពុជា (Rainbow Community Kampuchea - RoCK) ដែលរៀបចំកម្មវិធីមោទនភាពកម្ពុជាប្រចាំឆ្នាំ បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់។ ស្រីស្រឡាញ់ស្រី អ្នកប្តូរភេទ និងបុរសស្រឡាញ់បុរសជាច្រើននាក់ពាសពេញប្រទេស បច្ចុប្បន្នមានឱកាសក្នុងការជួបគ្នា ចងក្រងបណ្តាញ រៀបចំ និងបញ្ចេញក្តីបារម្ភរបស់ពួកគេនៅតាមវេទិកាសាធារណៈនានា។*

*តែទោះបីជាយ៉ាងណា ក៏មានឧបសគ្គនានាជាច្រើនចាប់តាំងពីការមិនទទួលស្គាល់ពីក្រុមគ្រួសារ ការរើសអើងពីសហគមន៍ រហូតដល់ការមិនអើពើពីសង្គម។ នាំងដទៃទៀតរួមមាន ឥរិយាបថអវិជ្ជមានចំពោះអ្នកស្រឡាញ់ភេទដូចគ្នា និងការការពាររបស់ច្បាប់នៅខ្សោយ។ ទោះបីជាមានវប្បធម៌អត់ឱនជាទូទៅក៏ដោយក្តី និងការដែលយុវជនមានទំនោរបើកចំហរនិងទទួលស្គាល់ច្រើនជាងមនុស្សចាស់ៗក្តី ប្រទេសកម្ពុជានៅតែជាសង្គមមួយអភិរក្ស។ ក្រុមអ្នកស្រលាញ់ភេទដូចគ្នា ស្វែងរកការទទួលស្គាល់តែភ័យខ្លាចការបដិសេធរបស់សង្គម។ ប៉ុន្តែសង្គមចាប់ផ្តើមពីគ្រួសារ។ ការផ្លាស់ប្តូរត្រូវតែចាប់ផ្តើមពីការទទួលស្គាល់នៅក្នុងគ្រួសារជាមុនសិន។*

**លោកជាសិល្បករ និងជាអ្នករៀបចំដែលមានចំណងភ្ជាប់យ៉ាងមាំជាមួយនឹងកម្ពុជា ក៏ដូចជាជាមួយបណ្តាសហគមន៍អន្តរជាតិដទៃទៀតតាមរយៈសកម្មភាពច្នៃប្រឌិតរបស់លោក។ តើលោកកំណត់ខ្លួនឯងថាជាសកម្មជន និងជាសិល្បករដោយរបៀបណា?**

*ខ្ញុំយល់ថាខ្លួនខ្ញុំជាសិល្បករច្រើនជាង ថ្វីបើការងារសិល្បៈរបស់ខ្ញុំកន្លងមកហាក់ដូចជាចូលរួមជាមួយសហគមន៍ក្នុងការពិភាក្សាអំពីបញ្ហាសង្គម និងលើកកម្ពស់សម្លេងជាសមូហភាព។ ខ្ញុំចូលចិត្តវ៉ានឹងព្រំដែនសិល្បៈ ពោលគឺទម្រង់របស់សិល្បៈ អ្នកណាអាចបង្កើតវាបាន ហើយវាអាចធ្វើអ្វីបានខ្លះក្នុងពិភពពិតដែលពោរពេញទៅដោយភាពអយុត្តិធម៌សង្គម។ ខ្ញុំក៏ចូលចិត្តផងដែរនូវដំណើរការសហការណ៍គ្នា ពីព្រោះខ្ញុំអាចស្វែងយល់យ៉ាងច្រើនពីមនុស្សដែលខ្ញុំធ្វើការជាមួយ។ ខ្ញុំចូលចិត្តរឿងរ៉ាវរបស់មនុស្ស។*

**តើគ្រួសារ និងសហគមន៍ មានន័យយ៉ាងដូចម្តេចចំពោះលោក?**

*គ្រួសារគឺជាអ្នកដែលខ្ញុំត្រលប់មកជួបនៅផ្ទះ។ សហគមន៍គឺជាអ្នកដែលខ្ញុំធ្វើការជាមួយ។ អ្នកទាំងពីរនេះ ធ្វើឱ្យខ្ញុំមានអារម្មណ៍ថាមានទីពំនាក់ និងគោលបំណងក្នុងជីវិតកាន់តែខ្លាំង។*

..........

តើអ្វីទៅជាគ្រួសារ? តើអ្វីជាចំណងដែលចងភ្ជាប់ពួកយើងពីមុននិងឥឡូវនេះ? មែនហើយ ក្តីស្រឡាញ់នេះគឺ *ធម្មតា* ។

**You are an artist and organizer with strong ties to Cambodia as well as many other international communities through your creative activities. How do you identify as an activist, and as an artist?**

*I see myself more as an artist, except my art practice so far tends to engage community in talking about social issues and promoting collective voices. I like challenging the boundaries of art— its form, who can make it, and what it can do in a real world full of social injustice. I also enjoy the collaborative process because I can learn so much from people I work with. I love human stories.*

**What does family and community mean to you?**

*Family is whom I come home to. Community is whom I work with. Both together make me feel a strong sense of belonging and purpose.*

..........

What constitutes family? What are the ties that bind us, then and now? Yes, this love is *thoamada*.





*អ្នកគោះទ្វារ* (២០១២)
ដោយ វុធ លីណូ
រូបថតឌីជីថលស៊ីព្រីន
១៨០ x ៦០ cm
ចំនួនបោះពុម្ព ៤ សន្លឹក + ពង្រាងរបស់សិល្បករ

**សាញ់៖** តែងតែមានហើយ ការរើសអើង ពាក្យចេកចចូច ធ្វើអោយយើងខឹង តែយើងពិចារណាទៅ គឺមកពីគេមិនដឹង គេមិនបានរៀន គេមិនយល់។ ពេលខ្លះគ្មានអ្នកណាថាអីផង តែយើងខ្លាចរអែងខ្លួនយើង... ក្នុងការចុះចងក្រងអ្នកស្រលាញ់ភេទដូចគ្នានេះ យើងមិនមែនពង្រីកក្មេងៗអោយក្លាយទៅជាអ្នកស្រលាញ់ភេទដូចគ្នានោះទេ គឺយើងចុះជួបនិងបណ្តុះបណ្តាលអ្នកស្រលាញ់ភេទដូចគ្នាចាស់ៗ ដែលគាត់អត់បានដឹង។ អ្នកខ្លះមានអារម្មណ៍ឯកោ ថាប្រហែលជាមានតែគាត់ប៉ុន្មានគូក្នុងស្រុកភូមិនេះទេមើលទៅ ដូច្នេះគាត់អត់ហ៊ានចេញទេ។ ដូច្នេះយើងចងក្រងឡើងដើម្បីអោយពិភពលោកដឹង... ដើម្បីអោយដឹងថាយើងជាអ្នកស្រលាញ់ភេទដូចគ្នាមិនមែនឯកោ ហើយមិនមែនមានតែនៅប្រទេសយើងនោះទេ។ អ្នកខ្លះឆ្ងល់ថា ហេតុអីក៏មានក្មេងៗអ្នកស្រលាញ់ភេទដូចគ្នាច្រើនម៉េះ? តើជាតិគីមីហូរចូល រឺក៏ពីឆ្លងពីជំនាន់អ៊ុនតាក់? អញ្ចឹងយើងចងក្រងអ្នកស្រលាញ់ភេទដូចគ្នាចាស់ៗហ្នឹង ដើម្បីបង្ហាញថា ចុះកាលពី ៤០-៥០ ឆ្នាំមុន តើមានជាតិគីមីណាហូរចូលមក? ហ្នឹងគឺមកពីចិត្តអារម្មណ៍យើង។

Vuth Lyno
*The Door Knocker*, 2012
Digital C-Print
180 x 60 cm
Edition of 4 + AP

**Sanh**: There is always discrimination, bullying words that make us angry. But when we think about it, it's because people don't know, they haven't studied, they don't understand. Sometimes, even when there is no one saying anything, we ourselves feel uncomfortable… When building a network of LGBT (lesbian, gay, bisexual and transgender), we don't make young people become gay, but just meet and run workshops with older LGBT who are not so aware. Some feel that they might be the only couple like this in the village, so they are afraid to come out. Therefore, we build a network to let the world know: to let all LGBTs know that they are not alone and that it doesn't happen only in our country. Some wonder why are there so many young people now who love the same sex? Has there been an influx of chemicals? Is it because of UNTAC? So we build a network of older LGBT people to show, well, 40 or 50 years ago, what chemicals were there then? Being LGBT comes just from our feeling.




jub jub !

*កូនស្រីរង់ចាំម្តាយ* (២០១២)
ដោយ រ៉ុធ លីណូ
រូបថតឌីជីថលស៊ីព្រីន
១៨០ x ៦០ cm
ចំនួនបោះពុម្ព ៤ សន្លឹក + ពង្រាងរបស់សិល្បករ

**ពិសី៖** ខ្ញុំនិងម៉ែជជែកគ្នាច្រើន ជាពិសេសជុំវិញបញ្ហាការស្រលាញ់ភេទដូចគ្នា។ គាត់តែងនិយាយថាវាខ្មាសគេ ខុសប្រពៃណី ខុសធម្មជាតិ តែខ្ញុំតែងសុំអោយគាត់អោយហេតុផលថាតើហេតុអីបានជាខុសធម្មជាតិ។ ជាទូទៅម៉ែនិយាយមិនឈ្នះខ្ញុំទេ គាត់ហត់ គាត់ក៏ខ្ជិលនិយាយ… តែខ្ញុំទទួលបានភាពកក់ក្តៅ ព្រោះម៉ែនិយាយថា អ្នកដទៃគេរិះគន់យើងមិនដែលចេះចប់ទេ ថ្ងៃណាមួយដែលគេហត់គេនឹងឈប់… ខ្ញុំរៀនពីម៉ែមួយទៀតដោយសារម៉ែខ្ញុំក៏ធ្លាប់ទទួលការទិទានពីអ្នកដទៃដែរ ទី១ជាស្ត្រីមេម៉ាយ ទី២ជាស្ត្រីធ្វើកងទ័ព។ ជាទូទៅក្នុងសង្គមខ្មែរ ស្ត្រីធ្វើទាហាននៅក្នុងចំណោម ៩៩ ភាគរយជាប្រុស គេអត់ថាជាស្ត្រីល្អទេ ហើយដើរចោលផ្ទះ ចោលកូនចៅបាត់ៗរាប់ឆ្នាំ។ ខ្ញុំតែងប្រាប់គាត់ថា ខ្ញុំមានមោទនភាពចំពោះគាត់ណាស់ ព្រោះស្ត្រីភាគច្រើនអត់អាចធ្វើអញ្ចឹងបានទេ ទៅលីកាំភ្លើងចូលព្រៃផង និងធ្វើជាពេទ្យទាហានផង។ ពេលទាហានត្រូវរបួសដាច់ជើងដាច់ដៃហូរឈាម ម៉ែខ្ញុំជាអ្នកសង្គ្រោះជីវិតគេ។ ខ្ញុំគិតថា ការសរសើរម៉ែខ្ញុំជាកំលាំងចិត្តអោយម៉ែខ្ញុំទទួលយកខ្ញុំដែរ។ ឧទាហរណ៍ ឥឡូវខ្ញុំថាខ្ញុំមិនមែនជាទាហានទេ តែខ្ញុំជាអ្នកចំបាំងម្នាក់ដែរ។ ខ្ញុំតែងតែប្រៀបធៀបនឹងជីវិតរបស់គាត់។ ខ្ញុំថា ខ្ញុំអត់កាន់កាំភ្លើងទេ តែខ្ញុំកាន់ចំណេះដឹង ខ្ញុំកាន់ប៊ិច។ កាលនោះម៉ែតស៊ូ ឥឡូវនេះដល់តួនាទីខ្ញុំម្តង។

Vuth Lyno
*The Waiting Daughter*, 2012
Digital C-Print
180 x 60 cm
Edition of 4 + AP

**Pisey**: Me and mom, we talk a lot, especially around the issue of loving the same sex. She usually used to say that it's embarrassing, doesn't conform with traditions, and isn't natural. But I asked her to give me a reason why it's not natural. Usually, mom didn't win the argument, and she got tired and left… But I received warmth from mom because she said that there are always people who criticise us, but one day when they get tired they will stop. I also learned from mom because she was criticised too, first as a widow and then as a female soldier. In general, in our society, a woman who serves in the army—where 99 per cent of soldiers are men—is not considered a good woman, since she has to leave her home and children behind for many years. I always told mom that I was proud of her, because not many women can do this: carry a gun in the battlefield, and be a military doctor. When soldiers were injured or lost their limbs, mom was one who saved their lives. I think my appreciation for mom inspired her to accept me. For example, now I say that I'm not a soldier, but I'm also a fighter. I always compare my life and hers. I say that I'm not carrying gun, but instead I'm carrying my knowledge and my pen. In the past, mom was struggling. Now it's my turn.





*អ្នកថែម្ដាយ* (២០១២)
ដោយ វុធ លីណូ
រូបថតឌីជីថលស៊ីព្រីន
១៨០ x ៦០ cm
ចំនួនបោះពុម្ព ៤ សន្លឹក + ពង្រាងរបស់សិល្បករ

**សុជា៖** ខ្ញុំដឹងថាខ្លួនឯងប្លែកមិនដូចក្មេងប្រុសឯទៀត នៅពេលខ្ញុំអាយុ ១០ ឆ្នាំ។ ដល់ពេលខ្ញុំបានអាយុ ១៩ ឆ្នាំ ខ្ញុំក៏ចាប់ផ្ដើមស្លៀកពាក់ជាស្រី។ សព្វថ្ងៃខ្ញុំលក់ផ្លែឈើ និងភេសជ្ជៈនៅក្នុងព្រំដែនថៃ បានម៉ាហូបនិងចិញ្ចឹមម្ដាយបងប្អូននិងខ្លួនឯង។

**វីរៈ៖** ពេលខ្ញុំមកដល់ប៉ោយប៉ែត ខ្ញុំបានស្គាល់មិត្តភក្តិជា MSM [បុរសស្រលាញ់បុរស] និង TG [អ្នកប្តូរភេទ] ជាច្រើន ហើយខ្ញុំក៏បានប្រលូកក្នុងជីវិតជា MSM ពេញបរិបូរ។ រួចខ្ញុំបានចាប់ផ្ដើមធ្វើការស្ម័គ្រចិត្តជាមួយ MSM និង ស្ត្រីធ្វើការក្នុងសេវាកំសាន្ត អប់រំអំពីបញ្ហាអេដស៍ កាមរោគ ការប្រើប្រាស់ស្រោម សិទ្ធិមនុស្ស និងអំពើហិង្សាផ្សេងៗ... ថ្វីត្បិតយើងនៅផ្ទះសំណង់អាណាធិបតេយ្យមែន តែអ្នកជិតខាងគេគោរពស្រលាញ់ពួកខ្ញុំណាស់ ដោយសារពួកយើងតស៊ូរកស៊ីទាំងបងប្អូនដើម្បីចិញ្ចឹមម្ដាយ មិនមែនដើរលេងឥតប្រយោជន៍នោះទេ ... ផ្ទះខ្ញុំទទួលអ្នកភេទទី ៣ ចេញចូលពីគ្រប់ខេត្តទាំងអស់ដែលឆ្លងកាត់ប៉ោយប៉ែតនេះ យើងរាប់អានទទួលអោយស្នាក់នៅ ទទួលបាយទឹក គឺមានអីហូបហ្នឹង។

**ម្ដាយរបស់សុជានិងវីរៈ៖** ដំបូងខ្ញុំដឹងពីសុជាមុន ពេលវាតែងខ្លួនស្រី បន្ទាប់មកទើបដឹងពីវីរៈ។ ពេលសុជាស្លៀកពាក់តែងខ្លួនស្រី វាចេះតែសួរខ្ញុំថាម៉ែស្អាតអត់។ មិនត្រឹមតែវាទេ អ្នកភេទទី ៣ ផ្សេងៗទៀតដែលឆ្លងកាត់ អោយតែស្លៀកពាក់ សួរតែម៉ែថាស្អាតអត់។ ថាម៉ែមិនចូលចិត្តហើយ ចេះតែសួរ សួរៗរហូតដល់ម៉ែបាក់ចិត្តទៅទាំងស្រុង។ ពេលដំបូង ខ្ញុំខឹងនិងសោកស្ដាយមិនចង់អោយកូនធ្វើបែបនេះទេ។ តែសព្វថ្ងៃនេះ វាទូទៅអញ្ចឹងហើយ ម្លោះហើយខ្ញុំក៏ទទួលស្គាល់ដែរ អោយតែកូនចេះរកស៊ីចិញ្ចឹមនៅថែម៉ែ ហើយមិនធ្វើអោយម៉ែពិបាកចិត្តព្រោះកូន។

Vuth Lyno
*The Mother Caretaker*, 2012
Digital C-Print
180 x 60 cm
Edition of 4 + AP

**Sothea:** I knew that I was different from other boys when I was 10. Later, when I was 19, I started dressing as a woman. Today, I sell fruits and drinks along the Thai border, just enough to eat and support my mother, siblings and myself.

**Virak**: When I came to Poipet I made many new friends who are MSM [men who have sex with men] and transgender, and I began to live my life fully as an MSM. I started to do voluntary work with MSM and women working in entertainment services, teaching them about AIDS, STDs, the use of condoms, and violence.... Even though we live in a shack, the neighbours respect and love us because we work hard and take care of our mother, not playing around uselessly.... We host LGBT people from all over who pass by Poipet. They stay and eat in our house; we eat what we have.

**Sothea's and Virak's mother**: At first, I knew about Sothea when he started dressing as a woman. Then I knew about Virak. When Sothea dressed as a woman, he always asked me 'Mother, am I pretty?' Not only him, but also LGBTs who dropped by our house, when they dressed up, they always asked me, 'Mother, am I pretty?' I didn't like that, but they kept asking until my heart totally fell for them. At first, I felt angry and regretful, not wanting my sons to act like this. But these days, it's common everywhere. So I accept them, as long as they work, earn money and take care and stay with their mother, and they don't make me feel troubled at heart.




KARA
International
S-18SM

*អ្នកសុំអំបិល* (២០១២)
ដោយ វ៉ុធ លីណូ
រូបថតឌីជីថលស៊ីព្រីន
១៨០ x ៦០ cm
ចំនួនបោះពុម្ព ៤ សន្លឹក + ពង្រាងរបស់សិល្បករ

**ស៊ីថា៖** ខ្ញុំជួបគ្រួសារខ្ញុំ ក្នុងជំនាន់ប៉ុលពត។ ខ្ញុំជួបគាត់ដំបូងពេលជីកប្រឡាយនៅទល់មុខគ្នា។ បន្ទាប់មកដល់ខែស្នូង ខ្ញុំទៅសុំអំបិលពីគាត់ គាត់មិនអោយគាត់យកដៃខ្ទប់ចានទៀត។ ខ្ញុំក៏គុំគាត់ និងគិតប៉ងចង់បានគាត់ជាប្រពន្ធ។ ក្រោយមកដល់ខែច្រូត យើងក៏បានជួបគ្នាទៀត ហើយក៏ចាប់ទាក់ទងរាប់អានស្រលាញ់គ្នាទៅ។ ស្រលាញ់គ្នាហ្នឹងវេទនាទៀត គេយាមយប់មិនអោយយើងស្គាល់ជួបគ្នាទេ។ គេយាមផ្លូវតាំងពីម៉ោង ១១ ដល់ម៉ោង ១ យប់ រហូតដល់អ្នកយាមថា អាណាទៅឯណាក៏ទៅៗ អញងងុយដេកណាស់។ ដូច្នេះ ខ្ញុំចាំរហូតដល់អ្នកយាមដេកលក់បាត់ ទើបបានជួបគ្នាទាល់តែបាន... ក្រោយពីបែក ៧៩ មក យើងមិនបានរៀបអាពាហ៍ពិពាហ៍អីទេ គ្រាន់តែសែនផ្គាប់ខ្មោចដូនតា និងចងដៃបាចផ្កាស្លា។ ខ្ញុំដើរបានតួនាទីជាមេគ្រួសារ ជាប្ដី ចំណែកគាត់ជាប្រពន្ធ ហើយយើងចិញ្ចឹមកូន បីនាក់ ស្រី ២ ប្រុស ១ និងមានចៅ ៦ នាក់។ កូនខ្ញុំតាំងពីតូចហៅខ្ញុំថាប៉ា និងចៅហៅខ្ញុំថាតា។

Vuth Lyno
*The Salt Seeker*, 2012
Digital C-Print
180 x 60 cm
Edition of 4 + AP

**Sitha**: I met my wife during the Pol Pot regime. I first met her when we were digging a canal opposite each other. After that, during rice transplanting month, I went to ask for some salt from her, but she refused: she even covered the salt bowl with her hand! So this stayed with me, and I thought about wanting her to be my wife. After that, during harvest month, we met again and started to talk, and then we fell in love. This love is difficult, because they guarded us and didn't let us meet. They guarded us from 11pm until 1am, and then the guard said, 'Who wants to meet who? I don't care, I'm so sleepy.' So I waited until the guard fell asleep then we met each other… After 1979, we didn't get married properly, we just prayed to our ancestors and people did the ritual of chorng-dai, tying threads around our wrists. I play the role of head of the family, as husband and with her as a wife, and we have adopted three children—two daughters and a son—and have six grandchildren. My children call me dad, and my grandchildren call me granddad.





*មនុស្សហោះហើរ* (២០១២)
ដោយ វុធ លីណូ
រូបថតឌីជីថលស៊ីព្រីន
១៨០ x ៦០ cm
ចំនួនបោះពុម្ព ៤ សន្លឹក + ពង្រាងរបស់សិល្បករ

**ម៉ាក់របស់សែម៖** ដំបូងពេលកូនប្រាប់ខ្ញុំ ខ្ញុំខឹងព្រោះកូនអត់តាមម្ដាយ។ ខ្ញុំចង់អោយកូនមានអនាគត មានគ្រួសារមួយល្អធូរជារ មានប្រពន្ធ មានកូនតពូជពង្សវង្សត្រកូល។ តែសុភមង្គល គឺស្ថិតនៅលើគេ។ ឧបមាបើខ្ញុំបង្ខំអោយគេរៀបការ គេមិនស្រលាញ់ រួចដើរចោលកូនគេ យើងត្រូវពិបាក។ ដូច្នេះតាមដំណើរទៅ កុំបាច់រាំងស្ទះទប់ទល់អី។ ខ្ញុំយកធម៌មកដាក់ខ្លួន។

**សែម៖** ដំបូងគាត់មិនយល់ថាតើហេតុអីបានជាខ្ញុំទៅស្រលាញ់ភេទដូចគ្នាទេ។ គាត់បានគិតថាខ្ញុំតាមគេ ហើយអ្នកខ្លះគិតថាជាជំងឺទៀងផង តែតាមពិតមិនមែនទេ គឺមកពីអារម្មណ៍។ សំខាន់ត្រូវពន្យល់គាត់ ព្រោះការយល់ចិត្តពីក្រុមគ្រួសារគឺជាកត្តាដ៏សំខាន់សំរាប់ជីវិតរបស់ខ្ញុំ បន្ទាប់ពីខ្ញុំយល់ខ្លួនឯង... ទំនាក់ទំនងនៅក្នុងគ្រួសារគឺសំខាន់។ យើងត្រូវបង្ហាញនូវចិត្ត និងអារម្មណ៍របស់យើងអោយច្បាស់អោយពួកគាត់យល់ ហើយយើងត្រូវព្យាយាមអប់រំគាត់ដែរ។

**ស្នា (ប្អូនស្រីរបស់សែម)៖** ពួកយើងតែងនាំគាត់អោយទៅឃើញពិភពលោកថ្មី។ រាល់ខែយើងតែងនាំគាត់ទៅហូបអាហារ និងកំសាន្តនៅខាងក្រៅ។ ដូច្នេះទៅ វាបើកចំហ ហើយគាត់ឃើញពិភពខាងក្រៅ។ បើយើងនៅតែក្នុងផ្ទះ យើងអត់ដឹងអីទេ។

Vuth Lyno
*The Flying Man*, 2012
Digital C-Print
180 x 60 cm
Edition of 4 + AP

**Mak Sam (Sam's mother)**: When my son first told me, I was angry because he didn't listen to me. I want him to have a future, and thought that this meant having a well-off family: a wife and kids continuing our family. But his happiness is up to him. If I forced him to get married, and he didn't love his wife and left her, then that would cause trouble. So I let him be, I didn't restrict him. I followed the dhamma in me.

**Sam**: At first my family didn't understand why I love the same sex. They thought maybe I was following others; some people even thought that it's a disease. But in fact it's not like that, it's a feeling. It's important, I needed to explain to them, because understanding and support from family is an important part of my life after I understood about myself… Communications within the family is important. We should express our feelings clearly to our family, and we should educate them too.

**Sna (Sam's sister)**: We often take our family to see the new world out there. Every month, we usually take them to restaurants or to hang out. So they go out and see the outside world. If we only stay in the house, we don't know anything.





*អ្នកមើលកូន* (២០១៣)
ដោយ វ៉ុធ លីណូ
រូបថតឌីជីថលស៊ីព្រីន
១៨០ x ៦០ cm
ចំនួនបោះពុម្ព ៤ សន្លឹក + ពង្រាងរបស់សិល្បករ

**ឃុនៈ** ក្នុងជំនាន់ប៉ុលពត មេកងគេចាប់ខ្ញុំអោយរៀបការ ហើយខ្ញុំបានកូនប្រុសមួយ។ ដល់ពេលបែកប៉ុលពត ខ្ញុំក៏បីកូនរត់គេចមក...ខ្ញុំបានរែកកូនមួយចំហៀង រែកព្រលឹតខ្យងមួយចំហៀងមកលក់នៅផ្សារ។ ក្រោយមក ខ្ញុំក៏ជួប គឿក នៅភូមិនេះ។ ដំបូង ខ្ញុំយកកូនមកផ្ញើគាត់ ហើយខ្ញុំលួចសង្កេតឃើញថាគាត់មានចិត្តល្អដល់កូនខ្ញុំ។ លុះក្រោយមកខ្ញុំក៏សុំគាត់រស់នៅជាមួយគ្នាទៅ។

**គឿក**ៈ ខ្ញុំដូចជាមាននិស្ស័យជាមួយគាត់។ មានគេចូលស្ដីដណ្ដឹងខ្ញុំដែរ តែខ្ញុំមិនពេញចិត្ត។ កាលនោះខ្ញុំបានចិញ្ចឹមក្មួយ ២ នាក់ និងថែទាំឪពុកឈឺ។ គាត់បានជួយមើលឪពុកខ្ញុំដែរ។ បន្ទាប់ពីឪពុកខ្ញុំស្លាប់បានប្រហែល ១ អាទិត្យមក ខ្ញុំក៏សម្រេចចិត្តយកគាត់នៅជាមួយគ្នារហូតមក។ អ្នកជិតខាងខ្លះធ្លាប់វាយតម្លៃយើងថាហេតុអីមកយកស្រីគ្នាឯង ខ្វះអីប្រុសមួយគំនរ តែខ្ញុំថានេះជាសិទ្ធិរបស់យើង។

Vuth Lyno
*The Babysitter*, 2013
Digital C-Print
180 x 60 cm
Edition of 4 + AP

**Khun**: During the Pol Pot regime, I had a forced marriage and had a baby boy. Once the Pot Pol regime ended, I carried my baby and ran away… I carried my baby on one side, and *prorlit* (waterlily stems) and snails on other, going to sell in the market. Later I met Phoeuk, here in this village. First I asked her to help babysit my son, and I noticed that she was kind to my son. So I asked to stay with her.

**Phoeuk**: I seemed to have a connection with Khun. There were men coming to propose to me, but I didn't like them. At that time, I was raising two nephews and taking care of my sick father. Khun helped take care of my father too. About one week after my father died, I decided to take Khun to live together. There were some neighbours judging us, asking why a woman loves a woman—there were plenty of men—but I said it's our right.





*អ្នកចំរៀង* (២០១២)
ដោយ វុធ លីណូ
រូបថតឌីជីថលស៊ីព្រីន
១៨០ x ៦០ cm
ចំនួនបោះពុម្ព ៤ សន្លឹក + ពង្រាងរបស់សិល្បករ

**ឈឿន៖** ខ្ញុំតែងនឹកដល់ពេលច្រៀងលេងកាលពីនៅតូច។ ខ្ញុំធ្លាប់យកសារ៉ុងម៉ែរីរបស់បងប្អូនមករុំស្លៀក ហើយច្រៀងលេងក្នុងភូមិ។ ខ្ញុំធ្លាប់សំដែងជាតួអង្គស្រីក្នុងល្ខោនក្នុងភូមិដែរ។ ខ្ញុំចាំថាបានច្រៀងក្នុងជំនាន់ប៉ុលពត។ កាលណោះពិបាកខ្លាំងណាស់ ហើយយើងតែងមានប្រជុំរាល់ពេលយប់បន្ទាប់ពីហូបអាហាររួច ហើយប្រជុំនោះគួរអោយធុញទ្រាន់។ ប៉ុន្តែខ្ញុំចូលចិត្តច្រៀងចំរៀងខ្មែរក្រហម។ ឥឡូវនេះ ខ្ញុំបានបង្រៀននៅសាលាបឋមសិក្សាក្នុងភូមិយើងនេះច្រើនឆ្នាំហើយ។ ខ្ញុំក៏ទទួលបន្ទុកគ្រប់គ្រងបណ្ណាល័យផងដែរ។ នៅចុងសប្តាហ៍ ខ្ញុំទៅរៀនបន្ថែមទៀតនៅទីរួមខេត្ត។

Vuth Lyno
*The Singer*, 2012
Digital C-Print
180 x 60 cm
Edition of 4 + AP

**Chhoeun**: I always remember about singing when I was young. I used to get a sarong from my mom or someone and sing in the village. I played a female role in *lakhaon* (Khmer opera). I also remember singing during the Pol Pot regime. That time was so difficult, even just the meetings every night after dinner I remember being so boring. But I liked to sing the Khmer Rouge songs. Now I have been teaching at our village's primary school for many years. I also take charge of the library. On the weekend I go to study in the provincial town.





*អ្នកសំអាងការ* (២០១៣)
ដោយ វ៉ុធ លីណូ
រូបថតឌីជីថលស៊ីព្រីន
១៨០ x ៦០ cm
ចំនួនបោះពុម្ព ៤ សន្លឹក + ពង្រាងរបស់សិល្បករ

**ដារ៉េត៖** កាលខ្ញុំនៅតូច គេប្រាប់ប៉ាខ្ញុំថាកូនហ្នឹងចាំមើលធំឡើងខ្ទើយហើយ។ ប៉ាខ្ញុំថាខ្ទើយក៏នៅជាកូនរបស់ គាត់ព្រោះគាត់ស្រលាញ់។ យើងគឺជាកញ្ចក់។ សង្គមតែងមើលមកយើង។ បើយើងធ្វើល្អ គេនឹងអោយតម្លៃយើងតាមហ្នឹងដែរ។ បើយើងមិនអោយតម្លៃខ្លួនយើង តើអ្នកណាអោយតម្លៃយើង? អញ្ចឹងបានជាខ្ញុំ ខំប្រព្រឹត្តអ្វីល្អៗក្នុងសង្គម។ ខ្ញុំចង់អោយគេទទួលស្គាល់ខ្ញុំ អញ្ចឹងខ្ញុំត្រូវទទួល ស្គាល់ខ្លួនខ្ញុំ ត្រូវអោយតម្លៃខ្លួនខ្ញុំ។ ខ្ញុំមិនរើសអើសខ្លួនខ្ញុំ ខ្ញុំមិនរើសអើងមិត្តភក្តិខ្ញុំ។ ខ្ញុំសង្ឃឹមថាសង្គមនឹងមើលឃើញតម្លៃរបស់យើងបើយើងធ្វើល្អ។

**ចន្ធី (បងថ្លៃរបស់ដារ៉េត)៖** ខ្ញុំបានសុំប្អូនខ្ញុំ ចំរើន អោយគិតអោយច្បាស់។ បើស្រលាញ់ប្រាប់ថាស្រលាញ់។ បើលេងសើចទេ ឈប់ទៅ ព្រោះថ្ងៃក្រោយយើងនឹង ធ្វើបាបចិត្តគេ និងនាំអោយគេមើលងាយយើង។ ចំរើន ថាគេស្រលាញ់ប្តូរផ្តាច់គ្នាហើយ។ ដំបូងម៉ាក់ខ្ញុំប្រកែក ប៉ុន្តែខ្ញុំជួយនិយាយថាកុំអោយបំបែកគេអី។ ដំបូង ដារ៉េត ទូរស័ព្ទមកខ្ញុំណែនាំខ្លួន។ ក្រោយមកយើងតែងដើរលេងជាមួយគ្នា… មានថ្ងៃមួយ គាត់ចុះក្នុងទស្សនាវដ្តី ខ្ញុំក៏ប្រាប់អ្នកនៅកន្លែងធ្វើការខ្ញុំថានេះជាប្អូនប្រុសរបស់ខ្ញុំ និងប្រពន្ធរបស់គេ។ គេសួរខ្ញុំថាប្រពន្ធហ្នឹងជាភេទទី ៣ រឺ? ខ្ញុំថា ចាស។ គេសួរចុះតើគេយកគ្នាម៉េចទៅ? ខ្ញុំថា អ្នកណាដឹង! អោយតែគេស្រលាញ់គ្នា។

Vuth Lyno
*The Make-up Artist*, 2013
Digital C-Print
180 x 60 cm
Edition of 4 + AP

**Dareth**: When I was young, they said to my father that this son will be gay when he grows up. My dad said, 'Even if he's gay, he's still my son and I love him.' We are like a mirror. Society looks at us. If we do well, they will value us. If we don't value ourselves, who will value us? That's why I try to do good things. I want people to accept me, so first I need to accept myself, value myself. I don't discriminate against myself. I don't discriminate against my friends. I hope society will see our value if we do good things.

**Chanthy (Dareth's sister-in-law)**: I asked my brother Chamrouen to think clearly, is it love or play? If it's play, please stop or you will break someone's heart and people will look down on us. He said they really love each other. First my mom refused. But I helped talk with mom not to separate them. First Dareth called me to introduce herself. Then we all hung out together all the time… One day I saw an article about Chamroeun and Dareth in a magazine, and I showed it to my colleagues, telling them this is my brother and his wife. They asked is the wife 'third gender?' I said yes. They asked how do they make love? I said, 'Who knows! As long as they love each other.'

# សេចក្តីថ្លែងអំណរគុណ

ពិនិត្យដោយ វុធ លីណូ
បកប្រែដោយ ស៊ុំ ស៊ីថែន និង វុធ លីណូ
រចនាសៀវភៅដោយ វុធ លីណូ

ផលិតដោយ សហគមន៍ឥន្ទធនូកម្ពុជា (RoCK)
ភ្នំពេញ ២០១៣

បោះពុម្ពដោយ រោងពុម្ព JSRC ភ្នំពេញ

វុធ លីណូ សូមថ្លែងអំណរគុណដល់៖
បុគ្គលនិងគ្រួសារទាំងអស់ដែលបានចូលរួមក្នុងគម្រោងរូបថតនេះ
អ្នកនិពន្ធទាំងអស់
ខ្វៃ សំណាង  លីម សុខចាន់លីណា  និង  រ៉ជឺ ណែលសិន
អេរិន ឃ្លីសុន និង ស-សបាសាក់
ខែម ពុទ្ធារី និង អេស.ប៉េ.កា ផ្តិតរូបនិងស្ទូឌីយ៉ូ
សេវ៉ាពិភពលោកអាមេរិកជ្វីស (AJWS)
ស្ថានទូតអង់គ្លេសភ្នំពេញ
ស្ថានទូតស៊ុយអែតភ្នំពេញ
Diakonia
ខុលលែត អូរីហ្គិន  លី ពិសី និង ស្រ៊ុន ស្រ៊ន
និង អ្នកទាំងអស់នៅ សហគមន៍ឥន្ទធនូកម្ពុជា (RoCK)

# Acknowledgements

Edited by Vuth Lyno
Translation by Sum Sithen and Vuth Lyno
Layout design by Vuth Lyno

Published by Rainbow Community Kampuchea (RoCK)
Phnom Penh, 2013

Printed at JSRC Printing House, Phnom Penh

Vuth Lyno thanks:
all the individuals and families who generously participate in this project,
the contributing authors,
Khvay Samnang, Lim Sokchanlina and Roger Nelson,
Erin Gleeson and SA SA BASSAC,
Khem Putheary and SPK Fuji Digital Image Center,
American Jewish World Service (AJWS),
the British Embassy Phnom Penh,
the Embassy of Sweden Phnom Penh,
Diakonia,
Collette O'Regan, Ly Pisey and Srun Srorn,
and all at the Rainbow Community Kampuchea (RoCK).

ផលិតដោយ
Published by

សហគមន៍ឥន្ទធនូកម្ពុជា
ROCK